# ព្រះរាជាណាចក្រកម្ពុជា

**តុលាការកំពូល**

**ជាតិ សាសនា ព្រះមហាក្សត្រ**

********

សំណុំរឿងរដ្ឋប្បវេណី

លេខ : ១២៦

ចុះថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០០១

សាលដីកា

លេខ : ១៧៥

ចុះថ្ងៃទី ០៦ ខែ វិច្ឆិកាឆ្នាំ២០០១

## នាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបើកសវនាការជំនុំជំរះ ជាសាធារណៈ នៅថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ២០០១

ដោយមានសមាសភាពដូចតទៅ :

១- ឯកឧត្តម **ឌិត មុន្ទី** ជាប្រធាន

២- លោក ជីវ កេង ជាចៅក្រម របាយការណ៍

៣- លោក ស៊ុន ឌីម ជាចៅក្រម

៤- លោក ប្រាក់ គឹមសាន ជាចៅក្រម

៥- លោក សោម សិរីវឌ្ឍ ជាចៅក្រម

ក្រឡាបញ្ជី

កញ្ញា ហុក សុខធុល

តំណាងអយ្យការ

លោក ប៉ែន សារឿន ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះ លើបណ្តឹងសាទុក្ខពីសាលដីកា លេខ ១០ " ខ " ចុះថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០០១ នៃ សំណុំរឿងរដ្ឋប្បវេណីលេខ ១៣៤ ចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០០០ របស់សាលាឧទ្ធរណ៍ ។

- រវាងម្ចាស់បណ្តឹងសាទុក្ខឈ្មោះ លោក សំ ផុន បានផ្ទេរសិទ្ធិឱ្យកូន ឈ្មោះ សំ វុទ្ធី ភេទប្រុស អាយុ ៣២ឆ្នាំ ជាតិខ្មែរ មុខរបរ មន្ត្រីនគរបាលសេដ្ឋកិច្ច ទីលំនៅផ្ទះលេខ ១២Eo ,១២ Zo+Z1 ផ្លូវ លេខ ៩ ក្រុម ១៦ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ក្រុងភ្នំពេញ ។

- និងម្ចាស់បណ្តឹងសាទុក្ខឈ្មោះ ប៉េន ចាន់ណា ភេទស្រី អាយុ ៤០ឆ្នាំ ជាតិខ្មែរ មុខរបរ លក់ដូរ ទីលំនៅ៖ ផ្ទះលេខ ១២ E1 ផ្លូវលេខ ៩ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ក្រុងភ្នំពេញ ។

- និងម្ចាស់បណ្តឹងសាទុក្ខឈ្មោះ ឱក បូរ៉ាស៊ី ភេទស្រី អាយុ ៤៨ឆ្នាំ ជាតិខ្មែរ មុខរបរ មេផ្ទះ ទីលំនៅ៖ ផ្ទះលេខ ១២ E1Z ផ្លូវលេខ ៩ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ក្រុងភ្នំពេញ ។

- និងម្ចាស់បណ្តឹងសាទុក្ខឈ្មោះ ខៀវ ម៉ន ភេទប្រុស អាយុ ៤៦ឆ្នាំ ជាតិខ្មែរ មុខរបរ បុគ្គលិកគ្រឿងយន្តកសិកម្ម ទីលំនៅ៖ ផ្ទះលេខ ៦ E1 ក្រុម ១៦ ផ្លូវលេខ ៩ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ក្រុងភ្នំពេញ ។

- និងម្ចាស់បណ្តឹងសាទុក្ខឈ្មោះ ព្រំ សុគន្ធី ភេទស្រី អាយុ ៣១ឆ្នាំ ជាតិខ្មែរ មុខរបរ

បុគ្គលិករដ្ឋាករទឹកភ្នំពេញ ទីលំនៅ៖ ផ្ទះលេខ ១០E₁ ក្រុមទី១៦ ផ្លូវលេខ ៥ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ក្រុងភ្នំពេញ ។

- អំពីវិវាទ : ប្តឹងសុំបើកច្រកផ្លូវ

បានឃើញបណ្តឹងសាទុក្ខលេខ ៣៥ ចុះថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០០១ របស់អ្នកស្រី រ៉េន ថាន់ណា ¸ អ្នកស្រី ឱក ប៊ូរ៉ាស៊ុី ¸ លោក ខៀវ ម៉ន ¸ អ្នកស្រី ព្រំ សុគន្ធី និង បណ្តឹងសាទុក្ខលេខ ៥៥ ចុះថ្ងៃទី ០៥ ខែ មីនាឆ្នាំ ២០០១ របស់លោក សំ វុទ្ធី ប្តឹងមិនសុខចិត្ត ពីសាលដីកាលេខ ១០ " ខ " ចុះថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០០១ របស់សាលាឧទ្ធរណ៍ លើសាលដីកាទាំងមូល ។

បានឃើញ សំណុំរឿងរដ្ឋប្បវេណីលេខ ១២៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០១ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹង របស់ដើមចោទលោក សំ វុទ្ធី ប្តឹងសុំឱ្យអ្នកស្រី រ៉េន ថាន់ណា ¸ លោក ខៀវ ម៉ន ¸ អ្នកស្រី ឱក ប៊ូរ៉ាស៊ុី ¸ អ្នកស្រី ព្រំ គន្ធី រុះរើសំណង់អាណាធិបតេយ្យលើច្រកខឿងហែម ចេញទុកសំរាប់ផ្លូវសាធារណៈ ។

បានឃើញ សាលក្រមរដ្ឋប្បវេណីលេខ ១៥ " ក " ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារ នៃ សេចក្តីសំរេចដូចតទៅ :

១- ទទួលពាក្យបណ្តឹងរបស់ឈ្មោះ សំ វុទ្ធី ចុះថ្ងៃទី ២៣-០៦-១៩៩៩ ទុកជាត្រឹមត្រូវ តាមទំរង់ និង គតិច្បាប់ ។

២- បង្គាប់ឱ្យឈ្មោះ រ៉េន ថាន់ណា រុះរើផ្ទះឈើផ្ទាល់ដីចំនួនមួយ ¸ ឈ្មោះ ខៀវ ម៉ន រុះរើផ្ទះឈើផ្ទាល់ដីចំនួនមួយ ¸ ឈ្មោះ ព្រំ សុគន្ធី រុះរើផ្ទះឈើផ្ទាល់ដីចំនួន ពីរ ¸ ឈ្មោះ ឱក ប៊ូរ៉ាស៊ុី រុះរើផ្ទះឈើនៅជាន់ទី ០១ ចំនួនមួយ និង ឈ្មោះ សំ ផុន រុះរើផ្ទះឈើនៅផ្ទាល់ដីចំនួនពីរ ដែលសាងសង់នៅលើចំណីដីឡូតិ៍ ដើម្បីទុកប្រើប្រាស់ជាប្រយោជន៍សាធារណៈ ។ ដោយបង្គាប់ឱ្យដើមចោទឈ្មោះ សំ វុទ្ធី ចេញប្រាក់ឧបត្ថម្ភក្នុងការរុះរើនេះ ឱ្យឈ្មោះ រ៉េន ថាន់ណា ចំនួនប្រាំរយដុល្លាអាមេរិក ¸ ឈ្មោះ ខៀវ ម៉ន ចំនួនមួយពាន់ដុល្លាអាមេរិក ¸ ឈ្មោះ ឱក ប៊ូរ៉ាស៊ុី ចំនួនប្រាំពីររយដុល្លាអាមេរិក ¸ ឈ្មោះ ព្រំ សុគន្ធី ចំនួន ១៤០០ " មួយពាន់បួនរយ " ដុល្លាអាមេរិក ។ សំណូមពរលើសពីនេះ បដិសេធចោល ។

៣- បង្គាប់ឱ្យឈ្មោះ រ៉េន ថាន់ណា ¸ ឈ្មោះ ខៀវ ម៉ន ឈ្មោះ ព្រំ សុគន្ធី ¸ ឈ្មោះ ឱក-ប៊ូរ៉ាស៊ុី រួមគ្នាបង់ប្រាក់ប្រដាប់ក្តីចំនួន ៧០០០រៀល គឺពន្ធចុះបញ្ជីក្តី និង ពន្ធហ្គឹងចំនួន ១៨០០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ២០០រៀល រង្វាន់អ្នកប្រគល់ដីកាកោះចំនួន ២០០០រៀល រង្វាន់សាក្សីចំនួន ៣០០០រៀល បូករួមចំនួន ៧០០០រៀល ប្រាក់នេះបានកាត់យកពីប្រាក់ ៧០០០រៀល ដែលដើមចោទបានបង់ទុករួចជាស្រេច ។

កាលបើប្តឹងសបណ្តឹងឧទ្ធរណ៍ បង្គាប់ឱ្យចុងចម្លើយប្រគល់ប្រាក់ ៧០០០រៀល ទៅដើមចោទវិញ ។

៤- សាលក្រមនេះ ជំនុំជំរះ និង ប្រកាសជាសាធារណៈ ចំពោះមុខដើមចោទ ចំពោះមុខចុងចម្លើយទាំងអស់សំរេច បើកផ្លូវប្តឹងឧទ្ធរណ៍ រយៈពេល ២ខែ គិតពីថ្ងៃប្រកាសសាលក្រមនេះតទៅ ។

បានឃើញ បណ្តឹងឧទ្ធរណ៍ លេខ ០២ "ជ" ចុះថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០០០ របស់លោក សំ វុទ្ធី ប្តឹងមិនសុខចិត្ត និងសាលក្រមរដ្ឋប្បវេណីលេខ ១៩ "ក" ចុះថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ លើត្រង់ចំណុចទីពីរ និង បណ្តឹងឧទ្ធរណ៍លេខ ០១ ( ជ ) ចុះថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០០០ របស់អ្នកស្រី ឱក បូរ៉ាស៊ី, អ្នកស្រី ព្រំ សុគន្ធី, អ្នកស្រី រ៉េន ថាន់ណា, លោក ខៀវ ម៉ន របស់តុលាការក្រុងភ្នំពេញ លើត្រង់ចំណុចទីមួយ និង ទីពីរ ។

បានឃើញ សាលដីការបៀបលេខ ០៣ "ខ" ចុះថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០០០ របស់ សាលាឧទ្ធរណ៍ ដែលសំរេចដូចតទៅ :

១- ចាត់របៀបដោយសុំឱ្យអាជ្ញាធរ វាយតម្លៃសំណង់អនាធិបតេយ្យនីមួយៗ ឡើងវិញ និងក្នុងករណីចាំបាច់ក្រុមប្រឹក្សាជំនុំជំរះ គប្បីចុះពិនិត្យដល់កន្លែងកើតហេតុ ។

២- សាលដីកានេះ ជំនុំជំរះ ជាសាធារណៈ ចំពោះមុខគូក្តី ។

បានឃើញ សាលដីការដ្ឋប្បវេណីលេខ ១០ "ខ" ចុះថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០០១ របស់សាលាឧទ្ធរណ៍ ដែលមាន ខ្លឹមសារ នៃ សេចក្តីសំរេច ដូចតទៅ :

១- ទទួលបណ្តឹងឧទ្ធរណ៍លេខ ០១ ចុះថ្ងៃទី ១២-០១-២០០០ របស់ចុងចម្លើយទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែទាស់នឹងគតិច្បាប់ត្រូវបដិសេធចោល ។

២- ទទួលបណ្តឹងឧទ្ធរណ៍លេខ ០២ ចុះថ្ងៃទី ១៤-០១-២០០០ របស់ដើមចោទទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ត្រង់សេចក្តីសំរេចស្តីពីបង្គាប់ឱ្យចេញប្រាក់ឧបត្ថម្ភ តែទាស់នឹងគតិច្បាប់ ត្រង់សេចក្តីសំរេច ស្តីពីបង្គាប់ឱ្យរុះរើផ្ទះ នៃ ចំណុចទី២ នៃ សាលក្រម ។

៣- ដំកល់សាលក្រមរដ្ឋប្បវេណីលេខ ១៩ ( ក ) ចុះថ្ងៃទី ២៩-១១-១៩៩៩ របស់តុលាការក្រុងភ្នំពេញ ទុកជាបានការ លើកលែងតែចំណុចទី ២ ត្រង់សេចក្តីបង្គាប់ឱ្យដើមចោទឈ្មោះ សំ វុទ្ធី ចេញប្រាក់ឧបត្ថម្ភក្នុងការរុះរើ គឺឱ្យ :

- ឈ្មោះ រ៉េន ថាន់ណា ចំនួន ២០០$US
- ឈ្មោះ ខៀវ ម៉ន ចំនួន ៥០០$US
- ឈ្មោះ ឱក បូរ៉ាស៊ី ចំនួន ៣០០$US
- ឈ្មោះ ព្រំ សុគន្ធី ចំនួន ៨០០$US

ក្រៅពីនេះ ដំកល់ទុកនៅដដែល ។

៤- រឹបអូសយកប្រាក់ប្រដាប់ក្តី ជាន់សាលាឧទ្ធរណ៍ ចំនួន ២៦.០០០៛ ដែលដើមចោទ និងចុងចម្លើយបានបង់រួចហើយគឺ : ពន្ធចុះបញ្ជីក្តី និង ពន្ធហ៊ឹង ៥១០០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់៩០០៛ រង្វាន់អ្នកប្រគល់ដីកាកោះ ១០.០០០៛ រង្វាន់អាជ្ញាធរតុលាការ ១០.០០០៛ ។

សាលដីកានេះ ជំនុំជំរះ និង ប្រកាសជាសាធារណៈ ចំពោះមុខគូក្តី បើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ ៣៩ ចុះថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០០១ របស់អ្នកស្រី រ៉េន ថាន់ណា, អ្នកស្រី ឌិក ប៉ូរ៉ាស៊ី, លោក ខៀវ ម៉ន, អ្នកស្រី ព្រុំ សុគន្ធី និង បណ្តឹងសាទុក្ខលេខ ៥៩ ចុះថ្ងៃទី ០៥ ខែ មីនាឆ្នាំ ២០០១ របស់លោក សំ វុទ្ធី ប្តឹងមិនសុខចិត្ត ពីសាលដីកាលេខ ១០ " ខ " ចុះថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០០១ របស់សាលាឧទ្ធរណ៍ លើសាលដីកាទាំងមូល ។

បានឃើញ សារណាការពារ ចុះថ្ងៃទី ២៣-៥-២០០១ របស់លោក សំ វុទ្ធី

បានឃើញ សារណាការពារ ចុះថ្ងៃទី ០៥-៦-២០០១ របស់អ្នកស្រី រ៉េន ថាន់ណា

បានឃើញ សារណាការពារ ចុះថ្ងៃទី ៣១-៥-២០០១ របស់អ្នកស្រី ឌិក ប៉ូរ៉ាស៊ី

បានឃើញ សារណាការពារ ចុះថ្ងៃទី ០៤-៦-២០០១ របស់លោក ខៀវ ម៉ន

បានឃើញ សារណាការពារ ចុះថ្ងៃទី ៣១-៥-២០០១ របស់អ្នកស្រី ព្រុំ សុគន្ធី

បានឃើញ សារណាតប ចុះថ្ងៃទី ២៣-៧-២០០១ របស់ លោក ខៀវ ម៉ន

បានឃើញ សារណាតប ចុះថ្ងៃទី ១៦-៧-២០០១ របស់ អ្នកស្រី ឌិក ប៉ូរ៉ាស៊ី

បានឃើញ សារណាតប ចុះថ្ងៃទី ១៧-៧-២០០១ របស់ អ្នកស្រី រ៉េន ថាន់ណា

បានស្តាប់ របាយការណ៍ របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ ថា :

សាលដីកា រដ្ឋប្បវេណីលេខ ១០ " ខ " ចុះថ្ងៃទី ០៥-០២-២០០១ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវ តាមទំរង់ និង គតិច្បាប់ហើយ ។

សូមក្រុមប្រឹក្សាជំនុំជំរះ មេត្តាពិនិត្យ និង សំរេច តាមច្បាប់ ។

បានស្តាប់ចម្លើយរបស់ អ្នកស្រី រ៉េន ថាន់ណា ឆ្លើយថា : កាលដើមឡើយ ខ្លួនមានបន្ទប់ទឹកតូចមួយ នៅពីលើផ្ទះ សំ វុទ្ធី ប៉ុន្តែដោយបន្ទប់ទឹកនោះបែកហូរទឹក ខ្លួនក៏រុះមកធ្វើខាងក្រោម សង់លើដីចំណីផ្លូវដែលនៅសល់ ចំពោះអ្នកសង់នោះគឺសុទ្ធតែមានផ្ទះនៅខាងលើទាំងអស់ ដែលមានការលំបាកដាក់សំភារៈ ។ ហើយកាលនោះ ឈ្មោះ សំ វុទ្ធី ក៏បានបិទផ្លូវនេះដែរ ព្រោះខ្លាចអាជ្ញាធរមកចាប់ទឹកកក ដែលខ្លួនលួចធ្វើលក់ ។ ខ្លួនសង់តាំងពីឆ្នាំ ១៩៨១ មកម្លេះ ពេលសង់នោះគ្មានទំនាស់នេះ ទើបតែពេល សំ វុទ្ធី មានលុយមកសង់ផ្ទះនៅខាងក្រោយ សំរាប់ជួលឱ្យស្នាក់នៅ ទើបឱ្យខ្លួនបើកផ្លូវនេះ ។ ខ្លួនសុខចិត្តរុះចេញ តែសូមឱ្យភាគីម្ខាងទៀតចេញលុយឱ្យខ្លួន មក ។

បានស្តាប់ចម្លើយរបស់ អ្នកស្រី ឌិក ប៉ូរ៉ាស៊ី ឆ្លើយថា : កាលដំបូង ឪពុករបស់ សំ វុទ្ធី បានស្រុះស្រួលគ្នាជាមួយប្តីប្រពន្ធខ្លួន ដោយគាត់ឱ្យខ្លួនសង់ផ្ទះពយ៉ោបនៅខាងលើ ឯគាត់សង់កូនផ្ទះខាងក្រោមយ៉ោបផ្ទះខ្លួន ។ ការសង់នេះ ពុំប៉ះពាល់ដល់ផ្លូវដើរអ្នកជិតខាងទេ នៅឆ្នាំ ១៩៩៨ សំ វុទ្ធី ដែលរស់នៅទួលគោក បានមកសង់ផ្ទះពីលើផ្ទះឪពុក សំ ផុន ក៏ពុំមានទំនាស់អ្វីកើតឡើងដែរ ។ ក្រោយពីបានជួល

ផ្ទះនេះឱ្យភ្ញៀវ ទើប សំ វុទ្ធី កើតមានគំនិតលោភលន់ ចង់បានចំណែដីរបស់គ្រួសារអ្នកនៅខាងលើ ហើយដើម្បីឱ្យទូលាយមុខផ្ទះរបស់ខ្លួន ក៏ធ្វើពាក្យប្តឹងទាំងបំពាន ដោយចោទថា ចំណីដីខាងលើជាផ្លូវ ឡើង ហែម ទៅវិញ ។ ខ្លួនសង់ផ្ទះនេះ សំរាប់រស់នៅ ខ្លួនសុំមិនរុះរើទេ ហើយលក់ក៏មិនលក់ដែរ ។

បានស្តាប់ចម្លើយរបស់ លោក ខៀវ ម៉ន ឆ្លើយថា : ខ្លួនបានសង់ផ្ទះនេះ តាំងពីឆ្នាំ១៩៨១ ហើយបានសង់តូបមួយសំរាប់រកស៊ីលក់ដូរផង ពេលសង់នោះ គ្មានទំនាស់ទេហើយ ខ្លួនក៏បានទុកផ្លូវសំរាប់ចេញចូលដើរដែរ រហូតដល់គាត់សង់ផ្ទះ ២ជាន់ ទើបប្តឹងឱ្យខ្លួនរុះរើផ្ទះនេះ គឺគាត់ចង់ពង្រីកផ្លូវឱ្យធំ ដើម្បីជាប្រយោជន៍របស់គាត់ ។ ខ្លួនសូមបញ្ជាក់ថា បើ សំ វុទ្ធី ឱ្យខ្លួនរុះរើផ្ទះនេះចេញ គឺត្រូវគិតថវិកាឱ្យខ្លួនសមស្រប បើពុំដូច្នេះទេ គឺគ្មានការរុះរើឡើយ ។

បានស្តាប់ចម្លើយរបស់ អ្នកស្រី ព្រំ សុគន្ធី ឆ្លើយថា : ផ្ទះនេះ ខ្លួនបានទិញបន្តពីម្ចាស់ដើម ដែលគាត់បានសង់ តាំងពីឆ្នាំ ១៩៨១ មក ការសង់នេះ ពុំប៉ះពាល់ដល់អ្នកដទៃ រី រដ្ឋ អំណាចមូលដ្ឋានទេ គឺសង់លើចំណីដីដែលទុកច្រកមួយសំរាប់ដឹក កង់-ម៉ូតូ អាចចេញចូលបានរហូតមក ដោយគ្មានទំនាស់អ្វីទេ ។ សូម្បីតែ ពូ សំផុន ជាឪពុក សំ វុទ្ធី ជាប្រធានក្រុមសម័យនោះ ក៏ពុំមានជំទាស់ ហើយគាត់បានសង់កូនផ្ទះនេះដែរ ។ ខ្លួនយល់ព្រមរុះរើផ្ទះនេះចេញ លុះត្រាតែ សំ វុទ្ធី ឱ្យជាលុយដូច ការសំរុះសំរួលនៅខ័ណ្ឌមានជ័យក្នុង ១ម ២ ៣០០៩ ។

បានស្តាប់ចម្លើយរបស់ លោក សំ វុទ្ធី ឆ្លើយថា : ខ្លួនសូមជំរាបថា សំណង់ដែលសង់នៅលើផ្លូវ ឡើងហែមនេះ មាន ៨,៩គ្រួសារ ធ្វើលើផ្លូវគ្មានផ្លូវដើរទៅក្រៅទេ ។ នៅឆ្នាំ ១៩៩០ ម្តាយ រ៉េន-ជាន់ណា បានមក សំ ជាឪពុកខ្លួន សំ ផុន ធ្វើបន្ទប់ទឹកមួយនៅលើផ្លូវដើរចេញ-ចូល ដោយដាក់ពាងទឹកសំរាប់ប្រើប្រាស់ឪពុកខ្លួន ក៏យល់ព្រមឱ្យដាក់ជាបណ្តោះអាសន្ន រហូតដល់សព្វថ្ងៃនេះ ហើយឈ្មោះ ព្រំ សុគន្ធីបានសង់ផ្ទះពីលើបណ្តាញលូ និង ច្រកចេញ-ចូលរួម មួយនៅក្រោមកាំជណ្តើររបស់ ឱក ប៉ូរ៉ាស៊ី សំណង់នេះមានបណ្តូលលូធំមួយនៅចំពាក់កណ្តាលផ្ទះ ។ ឯឈ្មោះ ខៀវ ម៉ន បានសង់លើបណ្តាញលូ ប្រើរួម និង ក្រោមបង្គោលភ្លើងសំរាប់ប្រើប្រាស់រួម សំណង់នេះជាសំណង់អណាធិបតេយ្យ បណ្តាលឱ្យមានការលំបាកនៅលើបណ្តាញភ្លើង និង លូ ។ ចំណែកឈ្មោះ ឱក ប៉ូរ៉ាស៊ី បានមកសុំឪពុកខ្លួន តសំយ៉ាបចេញនៅលើបណ្តាញលូ និង លើផ្លូវដើរ គឺតសំយ៉ាបជាបណ្តោះអាសន្ន ។ ពីឆ្នាំ ១៩៨៥ រហូតដល់ឆ្នាំ ១៩៩០ អ្នករស់នៅខាងលើ និង ខាងក្រោម ចេះតែសុំដាក់ធុងទឹកកកនៅលើគំលាតផ្លូវចេញ-ចូល ហើយអ្នកទាំងនោះចេះតែលួចសង់សំណង់អណាធិបតេយ្យ រហូតដល់បច្ចុប្បន្ន ។

ខ្លួនសុំចេញលុយឱ្យសំណង់២ គឺសំណង់មួយ ៣០០៩ ឯសំណង់២ទៀត ខ្លួនសុំមិនចេញលុយទេ ព្រោះអ្នកទាំង ២ បានមកសុំឪពុក ខ្លួនសាងសង់បណ្តោះអាសន្ន ។

បានស្តាប់ចម្លើយរបស់ អ្នកស្រី ព្រំ សុគន្ធី ឆ្លើយថា : លោក សំ វុទ្ធី និយាយខុសពីពាក្យពិតទាំងអស់តាមពិត ឈ្មោះ ព្រំ ម៉ាលី បានប្តឹងសុំឱ្យគាត់បើកច្រកចេញ-ចូល នៅពេលដែល សំ វុទ្ធី ខឹងគេប្តឹង គាត់ក៏ខឹងដល់ផ្ទះគេផ្សេងទៀត ហើយក៏ប្តឹងសុំឱ្យបើកច្រកចេញ-ចូលទាំងអស់នេះទៅ ។ សំណង់

នេះម្ចាស់ដើមគេបានសង់តាំងពីឆ្នាំ១៩៨៤ មក ខ្លួនសុំឱ្យដោះស្រាយឱ្យបានសមស្រប ដើម្បីសង់ជាជំរកបាន ។

- ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចម្លើយ ដោះសាររបស់គូភាគី
- ក្រោយពីបានពិភាក្សា ត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៣៩ ចុះថ្ងៃទី ០៥-០២-២០០១ របស់អ្នកស្រី រ៉េន ជាន់ណា , អ្នកស្រី ឱក ប៉ូរ៉ាសី , លោក ខៀវ ម៉ន , អ្នកស្រី ព្រំ សុគន្ធី និង បណ្តឹងសាទុក្ខលេខ ៥៩ ចុះថ្ងៃទី ០៥-៣-២០០១ របស់លោក សំ វុទ្ធី ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះ មកជំនុំជំរះបានតាមមាត្រា ១៤ នៃច្បាប់ ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា ទីតាំងទំនាស់នេះ ជាច្រកចេញចូលរួម ដែលតាមលិខិតលេខ ១៤៩ ឆ.ត.ស ចុះថ្ងៃទី ២៥-០១-២០០១ របស់អាជ្ញាធររាជធានីភ្នំពេញ បញ្ជាក់ថា សំណង់លើទីតាំងទំនាស់ ជាសំណង់គ្មានច្បាប់ មិនចេញកម្មសិទ្ធិឱ្យទេ ហើយឱ្យអ្នកពាក់ពន្ធ រុះរើសំណង់ទាំងនេះ ដោយគ្មានលក្ខខ័ណ្ឌ ។

- យល់ឃើញថា ការដែលអ្នកស្រី រ៉េន ជាន់ណា , អ្នកស្រី ព្រំ សុគន្ធី , អ្នកស្រី ឱក ប៉ូរ៉ាសុី និង លោក ខៀវ ម៉ន លើកឡើងក្នុងសារណារបស់អ្នកស្រី និង របស់លោក ថា សំណង់ទាំងនេះបានសង់យូរមកហើយ ហើយការសង់នេះ ដើម្បីសំរួលដល់ការទុកដាក់សំភារៈប្រើប្រាស់ ហើយអ្នកស្រី និង លោកពុំសុខចិត្តនឹងការសំរេចរបស់សាលាឧទ្ធរណ៍នោះ តុលាការកំពូល ពុំអាចពិចារណាបានឡើយ ពីព្រោះអាជ្ញាធរ និង អង្គភាពជំនាញនានាដូចជា : ការិយាល័យភូមិបាលខណ្ឌចំការមន , ចៅសង្កាត់ទន្លេបាសាក់ , ប្រធានមន្ទីរសាធារណការ និង ដឹកជញ្ជូនរាជធានីភ្នំពេញ , ប្រធានអង្គភាពលូទឹក បូមទឹកក្រុងភ្នំពេញ និង ប្រតិភូរាជរដ្ឋាភិបាលរាជធានីភ្នំពេញ សុទ្ធតែបញ្ជាក់ថា សំណង់លើទីតាំងទំនាស់នេះ ជាសំណង់ខុសច្បាប់ ដែលគប្បីរក្សាទុកទីតាំងនេះ ជាច្រកចេញចូលរួម និង ដើម្បីងាយស្រួលថែទាំលូពញ្ញ ។

- យល់ឃើញថា ការដែលលោក សំ វុទ្ធី តំណាងឱ្យលោក សំ ផុន លើកឡើងក្នុងសារណា ចុះថ្ងៃទី ២៣-៥-២០០១ របស់លោកថា ទីតាំងទំនាស់នេះ ជាច្រកផ្លូវចេញ-ចូល សំរាប់ប្រជាជន ៩គ្រួសារ ហេតុនេះហើយ បានជាលោកមិនសុខចិត្តក្នុងការដែលតុលាការក្រុងភ្នំពេញ និង សាលាឧទ្ធរណ៍ សំរេចឱ្យលោក ឧបត្ថម្ភប្រាក់ទៅចុងចម្លើយនោះ ជាការពុំត្រឹមត្រូវទេ ពីព្រោះសំណង់នេះបានសាងសង់និងប្រើប្រាស់ជាយូរមកហើយ ដើម្បីសំរួលដល់ជីវភាពរស់នៅរបស់ចុងចម្លើយ ។

- យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ ១០ " ខ " ចុះថ្ងៃទី ០៥-០២-២០០១ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ហើយ ។

## ហេតុដូច្នេះ

# វិនិច្ឆ័យសេចក្តីចំពោះមុខក្តី

១- ទទួលបណ្តឹងសាទុក្ខលេខ ៣៩ ចុះថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០០១ របស់ អ្នកស្រី រ៉ែន ផាន់ណា , អ្នកស្រី ឱក បូរ៉ាស៊ី , លោក ខៀវ ម៉ន , អ្នកស្រី ព្រំ សុគន្ធី និង បណ្តឹងសាទុក្ខលេខ ៥៩ ចុះថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០០១ របស់លោក សំ វុទ្ធី ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោល ដោយខុសនឹងគតិច្បាប់ ។

២- តម្កល់សាលដីការដ្ឋប្បវេណីលេខ ១០ ( ខ ) ចុះថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០០១ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

៣- រឹបអូសប្រាក់ប្រដាប់ក្តីចំនួន ៣៨.០០០រៀល ដែលលោក សំ វុទ្ធី បានបង់រួចហើយគឺ :

- ពន្ធចុះបញ្ជីក្តី និង ពន្ធប្តឹងចំនួន ៤០០០រៀល ប៉ុន្តែប្រាក់នេះ ត្រូវកាត់ចំនួន ៨០០រៀល សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់,

- ចំណាយលើកិច្ចប្រគល់ដីកាកោះ ចំនួន ១៥.០០០រៀល សរុប ១៩.០០០រៀល នៅសល់ ១៩.០០០រៀល បង្វិលឱ្យលោក សំ វុទ្ធី ហើយតម្រូវឱ្យចុងចម្លើយសងប្រាក់ ៨៥០០រៀល ទៅដើមចោទវិញ ។

៤- សាលដីកានេះ ប្រកាសនាសវនាការ ជាសាធារណៈ នៅថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ២០០១ ។